# គោលការណ៍ណែនាំ

# ស្តីពី

# ការរៀបចំកន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះ

# ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ

សហការរៀបចំដោយ៖ ក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាល

ឆ្នាំ២០២៤

# គោលការណ៍ណែនាំ

# ស្តីពី

# ការរៀបចំកន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះ

# ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ

**សហការរៀបចំដោយ៖ ក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាល**

**ឆ្នាំ២០២៤**

# អារម្ភកថា

គោលការណ៍ណែនាំស្ដីពី ការរៀបចំកន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ មានគោលបំណងលើកកម្ពស់ការអនុវត្តការផ្តល់សេវាដោយមានការគោរពអភិក្រមសិទ្ធិមនុស្ស ការធានាសុវត្ថិភាព ការពង្រឹងភាពអង់អាច ឥរិយាបថមិនស្ដីបន្ទោស និងមិនធ្វើការវិនិច្ឆ័យ ការរក្សាឯកជនភាពនិងការសម្ងាត់ និងការមិនរើសអើង ជាពិសេសតម្រង់ទិសក្នុងការរៀបចំកន្លែងផ្តល់សេវាចម្រុះសម្រាប់ជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ តាមបទដ្ឋានសមស្រប និងឆ្លើយតបចំពោះតម្រូវការរបស់ជនរងគ្រោះ ដោយគោរពសេចក្តីថ្លៃថ្នូរ និងគ្មានការរើសអើង។

រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកការលើកកម្ពស់ការសម្របសម្រួលសេវា និងការឆ្លើយតបចំពោះស្ត្រីនិងក្មេងស្រីដែលទទួលរងអំពើហិង្សាជាអាទិភាពដូចមានចែងនៅក្នុងផែនការសកម្មភាពជាតិស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ និងអនុសាសន៍របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានថ្លែងក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៨ និងយោងលិខិតលេខ ៣៣៥ សជណ.អវ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ ជម្រាប ជូនក្រសួងសុខាភិបាល និងក្រសួងកិច្ចការនារី ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ បង្កើតកន្លែងផ្តល់សេវាចម្រុះ (កន្លែងតែមួយ) សម្រាប់ជួយស្ត្រី និងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សាគ្រប់ទម្រង់ ដើម្បីសម្រួលការផ្ដល់សេវាផ្នែកច្បាប់ សេវាសង្គមកិច្ច សេវាសុខភាព និងសេវាផ្សេងទៀតជូនជនរងគ្រោះ និងលិខិតលេខ១២៣ អបស/មព រដ្ឋមន្ត្រីក្រសួងសុខាភិបាលជម្រាបមកឯកឧត្តម អគ្គនាយកមន្ទីរពេទ្យកាល់ម៉ែត និងលោក លោកស្រី ប្រធានមជ្ឈមណ្ឌលជាតិ ប្រធានមន្ទីរពេទ្យជាតិ និងលោក លោកស្រី ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្តបង្កើតកន្លែងផ្តល់សេវាចម្រុះ (កន្លែងតែមួយ) សម្រាប់ស្ត្រីនិងក្មេងស្រី ដែលរងគ្រោះដោយអំពើហិង្សាគ្រប់ទម្រង់ ដើម្បីសម្រួលការផ្តល់សេវាផ្នែកច្បាប់ សេវាសង្គមកិច្ច សេវាសុខាភិបាល និងសេវាផ្សេងទៀតជូនជនរងគ្រោះ ត្រូវសហការជាមួយក្រសួងកិច្ចការនារី និងស្ថាប័នមន្ទីរពាក់ព័ន្ធ នៅក្នុងមូលដ្ឋានរបស់ខ្លួនពិសេសអាជ្ញាធរមូលដ្ឋាន។

ប្រទេសកម្ពុជាមានក្របខ័ណ្ឌច្បាប់ និងគោលនយោបាយជាតិសម្រាប់កិច្ចការពារសិទ្ធិស្ត្រី និងក្មេងស្រីមានលក្ខណៈល្អប្រសើរដើម្បីឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី និងក្មេងស្រី ឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា មានជាអាទិ៍ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឆ្នាំ២០០៥ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលទាំង៤ដំណាក់កាល យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៩-២០២៣ និងឯកសារគតិយុត្តជាច្រើនទៀត។

គោលការណ៍ណែនាំនេះរៀបចំឡើង ដើម្បីតម្រង់ទិសដល់អ្នកពាក់ព័ន្ធក្នុងការរៀបចំកន្លែងផ្តល់សេវាចម្រុះសម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ តាមបទដ្ឋានសមស្រប និងឆ្លើយតបចំពោះ

តម្រូវការរបស់ជនរងគ្រោះ ដោយគោរពសេចក្តីថ្លៃថ្នូរ និងគ្មានការរើសអើង។ កន្លែងផ្តល់សេវាចម្រុះនេះ គឺបំពេញបន្ថែមលើយន្តការដែលមានស្រាប់ ដែលមានក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅតាមបណ្តាខេត្ត១១ និង៥១ស្រុក ក្នុងគោលបំណងផ្តល់សេវាជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ឱ្យមានប្រសិទ្ធភាព ទាន់ពេលវេលា និងប្រកបដោយបរិយាបន្ន។

ក្រសួងកិច្ចការនារី សូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ និងក្រុមការងារក្រសួងកិច្ចការនារី ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុមប្រឹក្សាសកម្មភាពជនពិការ និងថ្នាក់ដឹកនាំ និងក្រុមការងារជំនាញនៅថ្នាក់ក្រោមជាតិ ដែលបានចូលរួមផ្តល់ធាតុចូលលើគោលការណ៍ណែនាំនេះ ដើម្បីឱ្យមានខ្លឹមសារសមស្រប និងអនុវត្តបាន។ ជាពិសេសសូមថ្លែងអំណរគុណជូន ចំពោះ **លោកជំទាវ ថ្នាក់ដឹកនាំទទួលបន្ទុក**ដែលបានផ្តល់ការគាំទ្រ និងជំរុញដំណើរការរៀបចំគោលការណ៍ណែនាំនេះឱ្យទទួលបានជោគជ័យនិងសូមថ្លែងអំណរគុណចំពោះមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន(UNFPA) ប្រចាំប្រទេសកម្ពុជា និងថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិក និងគម្រោងលើកកម្ពស់គុណភាពសេវាថែទាំសុខភាពរបស់ទីភ្នាក់ងារជំនួយអាមេរិក(USAID-EQHA) អនុវត្តដោយអង្គការ FHI360 អង្គការ Vital Strategies និងស្ថានទូតអូស្ត្រាលីតាមរយៈកម្មវិធី ACCESS 2 ដែលការផ្តល់កិច្ចគាំទ្រ ទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់ដំណើរការក្នុងការរៀបចំ បោះពុម្ពនិងផ្សព្វផ្សាយជាផ្លូវការ។

ក្រសួងកិច្ចការនារីមានជំនឿ និងសង្ឃឹមយ៉ាងមុតមាំថា គោលការណ៍ណែនាំស្តីពីការរៀបចំកន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ នេះនឹងក្លាយ ជាឧបករណ៍ដ៏មានសារៈសំខាន់សម្រាប់ជាជំនួយស្មារតីដល់អ្នកពាក់ព័ន្ធក្នុងការបង្កើតកន្លែងផ្តល់សេវាចម្រុះ ឆ្លើយតបចំពោះជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅតាមមន្ទីរពេទ្យរាជធានី ខេត្ត។

ថ្ងៃព្រ ៣រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**បណ្ឌិត អ៊ីង កន្ថាផាវី**

# មាតិកា


ពាក្យបំព្រួញ

អារម្ភកថា

សារតា ........................................................................ ១

១. គោលបំណង........................................................................ ៣

២. ស្ថានភាពអំពើហិង្សាលើស្ត្រីក្នុងប្រទេសកម្ពុជា........................................ ៣

៣. សេវាឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ.................................... ៦

៤. កន្លែងផ្តល់សេវាចម្រុះ........................................................................ ៨

៥. វិសាលភាព និងដែនកំណត់........................................................................ ៨

៦. នីតិវិធីក្នុងការរៀបចំកន្លែងផ្តល់សេវាចម្រុះ........................................ ៩

៧. សមាសភាព និងតួនាទី ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ និងអ្នកផ្តល់សេវា........................ ១៤

៨. បរិយាកាសនៃការអនុវត្តនៅកន្លែងផ្តល់សេវាចម្រុះ និងលំហូរនៃការបញ្ជូនជនរងគ្រោះ...... ............... ១៦

៩. ការអភិវឌ្ឍសមត្ថភាពសមាជិកក្រុមការងារ និងអ្នកផ្តល់សេវាពាក់ព័ន្ធ.................................. ១៩

១០. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ........................................................ ២០

ឯកសារយោង........................................................................ ២៣

# ពាក្យបំព្រួញ

| | | |
|---|---|---|
| Domestic Violence | DV | អំពើហិង្សាក្នុងគ្រួសារ |
| Gender Based Violence | GBV | អំពើហិង្សាទាក់ទងនឹងយេនឌ័រ |
| Intemate Partner Violence | IPV | អំពើហិង្សាពីដៃគូស្និទស្នាល |
| Lesbian, Gay, Bisexual, Transgender | LGBT | ស្ត្រីស្រឡាញ់ភេទដូចគ្នា បុរសស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកក្លែងភេទ |
| National Action Plan on Violence Againt Women | NAPVAW | ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី |
| One Stop Service Unit | OSSU | កន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ |
| Violence Againt Women | VAW | អំពើហិង្សាលើស្ត្រី |

# សារចនា

យុទ្ធសាស្ត្រអាទិភាពរបស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា បានលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចគាំពារសង្គម ដើម្បីពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងពង្រឹងតួនាទីស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ។ ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានយកចិត្តទុកដាក់ខ្ពស់ក្នុងការបង្កើនការវិនិយោគលើសមភាពយេនឌ័រ និងការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។ ក្របខណ្ឌច្បាប់ គោលនយោបាយ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តជាច្រើន ត្រូវបានដាក់ចេញដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជាក៏ដូចជាការប្តេជ្ញាក្នុងការលុបបំបាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រឱ្យធ្លាក់ដល់កម្រិតទាបបំផុតនៅឆ្នាំ២០៣០ ដែលរាជរដ្ឋាភិបាលកម្ពុជារួមជាមួយនឹងប្រទេសជាង១៨០ប្រទេស បានធ្វើការប្តេជ្ញាចិត្តនៅសន្និសីទអន្តរជាតិ ស្តីពី ប្រជាជននិងការអភិវឌ្ឍន៍នៅទីក្រុងណៃរ៉ូប៊ី ប្រទេសកេនយ៉ា កាលពីចុងឆ្នាំ២០១៩ ថានឹងសម្រេចឱ្យបានសូន្យចំនួនបីនៅឆ្នាំ២០៣០ គឺទី១ ការលុបបំបាត់អត្រាមរណភាពមាតាដែលអាចការពារបាន ទី២ ការលុបបំបាត់នូវតម្រូវការមធ្យោបាយពន្យារកំណើតដែលមិនបានសម្រេច និងទី៣ ការលុបបំបាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ។

តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កាលពីឆ្នាំ២០១៨ និងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៩-២០២៣ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងកិច្ចការនារីជាសេនាធិការ និងជាយន្តការថ្នាក់ជាតិក្នុងការសម្របសម្រួលការលើកកម្ពស់សមភាពយេនឌ័រ និងការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រីគ្រប់ទម្រង់ក្នុងប្រទេសកម្ពុជាបានសហការជាមួយក្រសួងសុខាភិបាល ក្នុងការរៀបចំកន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ បន្ថែមលើយន្តការដែលមានស្រាប់ គឺក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅតាមបណ្តាខេត្តមួយចំនួន។

ការលើកកម្ពស់ការឆ្លើយតប និងការសម្របសម្រួលផ្តល់សេវាជូនស្ត្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រជាសកម្មភាពអាទិភាពសម្រាប់កន្លែងផ្តល់សេវាចម្រុះ និងក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ស្របតាមផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣។ អំឡុងពេលនៃការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៤-២០១៨កន្លងមក កន្លែងផ្តល់សេវាចម្រុះជួយរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ត្រូវបានបង្កើត និងអនុវត្តសាកល្បងនៅក្នុងខេត្តចំនួន២ គឺខេត្តកំពង់ចាម និងខេត្តស្ទឹងត្រែង។ កន្លែងផ្តល់សេវាចម្រុះនេះ បានចូលរួមកែលម្អការសម្រប

និងទាន់ពេលសម្រាប់ស្ត្រីដែលទទួលរងអំពើហិង្សា

សម្រួលឆ្លើយតប និងគុណភាពសេវាកាន់តែប្រសើរ ទាក់ទងនឹងយេនឌ័រ។ គិតត្រឹមឆ្នាំ២០២៤ កន្លែងផ្តល់សេវាចម្រុះបានកើនដល់ចំនួន៧ខេត្ត (ខេត្តកំពង់ចាម ស្ទឹងត្រែង ព្រះវិហារ ត្បូងឃ្មុំ បាត់ដំបង កំពង់ឆ្នាំង និងរាជធានីភ្នំពេញ)។

កន្លែងផ្តល់សេវាចម្រុះ ត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រទី២ "ការការពារផ្នែកច្បាប់និងសេវាកម្មពហុវិស័យ"នៃផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី៣(២០១៩-២០២៣)និងយោងអនុសាសន៍របស់**សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីកាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៨ និងយោងលិខិតលេខ៣៣៥ សជណ.អវបុះ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ ជម្រាបជូនក្រសួងសុខាភិបាល និងក្រសួងកិច្ចការនារី ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ បង្កើតមណ្ឌលផ្តល់សេវាចម្រុះ (កន្លែងតែមួយ) សម្រាប់ស្ត្រីនិងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សាគ្រប់ទម្រង់ ដើម្បីសម្រួលការផ្តល់សេវាផ្នែកច្បាប់ សេវាសង្គមកិច្ច សេវាសុខភាព និងសេវាផ្សេងៗទៀតជូនជនរងគ្រោះ និងលិខិតលេខ១២៣ អបស/មព រដ្ឋមន្ត្រីក្រសួងសុខាភិបាលជម្រាបមក ឯកឧត្តមអគ្គនាយកមន្ទីរពេទ្យកាល់ម៉ែត និងលោក លោកស្រី ប្រធានមជ្ឈមណ្ឌលជាតិ ប្រធានមន្ទីរពេទ្យជាតិ និងលោក លោកស្រី ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្តបង្កើតកន្លែងផ្តល់សេវាចម្រុះ(កន្លែងតែមួយ)សម្រាប់ស្ត្រីនិងក្មេងស្រី ដែលរងគ្រោះដោយអំពើហិង្សាគ្រប់ទម្រង់ ដើម្បីសម្រួលដល់ការផ្តល់សេវាផ្នែកច្បាប់ សេវាសង្គមកិច្ច សេវាសុខភាព និងសេវាផ្សេងៗទៀតជូនជនរងគ្រោះ ដោយត្រូវសហការជាមួយក្រសួងកិច្ចការនារី និងស្ថាប័ន មន្ទីរពាក់ព័ន្ធនៅក្នុងមូលដ្ឋានរបស់ខ្លួនពិសេសអាជ្ញាធរមូលដ្ឋាន។

## ប្រភេទនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី

### អំពើហិង្សាផ្លូវកាយ

- ការរុញ
- ការច្រាន
- ការវាយដំ
- ការទះកំភ្លៀង
- ការវាយដំជាមួយនឹងវត្ថុអ្វីមួយ
- ការចោលនឹងវត្ថុអ្វីមួយ
- ទង្វើផ្សេងទៀត ដើម្បីប៉ុនប៉ងបង្កគ្រោះថ្នាក់

### អំពើហិង្សាផ្លូវចិត្ត

- ការស្រែក
- ការជេរប្រទេច
- ការប្រមាថមើលងាយ
- ការធ្វើឱ្យអាម៉ាស់
- ការរិះគន់
- ការគំរាមកំហែង
- ការប្រច័ណ្ឌខ្លាំង

### អំពើហិង្សាផ្លូវភេទ

- ការនិយាយលែបខាយផ្លូវភេទដែលគេមិនចង់បាន
- ការប៉ះពាល់ដែលគេមិនចង់
- មានចេតនារំលោភ
- បង្ខំជនរងគ្រោះឱ្យប្រព្រឹត្ត ទង្វើផ្លូវភេទ
- បង្ហាញរាងកាយរទៅកាន់ជនរងគ្រោះ
- រំលោភ (បញ្ចូលអង្គជាតិទៅក្នុងរាយកាយជនរងគ្រោះ)
- បង្ខំឱ្យមើលរឿង/រូបភាពអាសអាភាស

### អំពើហិង្សាផ្នែកសេដ្ឋកិច្ច

- ការបដិសេធមិនផ្តល់ឱ្យដៃគូគ្រប់គ្រងធនធានជាមូលដ្ឋាន
- ការបដិសេធមិនផ្តល់មូលនិធិ
- ការបដិសេធមិនរួមចំណែកក្នុងរឿងហិរញ្ញវត្ថុ
- ការបដិសេធបំពេញតម្រូវការជាមូលដ្ឋាន និងអាហារ
- ការត្រួតត្រាលើការប្រើប្រាស់សេវាថែទាំសុខភាព និងភាពមានការងារធ្វើ

## ១. គោលបំណង

**ការបង្កើត**គោលការណ៍ណែនាំស្តីពី ការរៀបចំកន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ៖

- លើកកម្ពស់ការអនុវត្តគោលការណ៍ ការគោរពអភិក្រមសិទ្ធិមនុស្ស ការធានាសុវត្ថិភាព ការពង្រឹងភាពអង់អាច ឥរិយាបថមិនស្តីបន្ទោសនិងមិនធ្វើការវិនិច្ឆ័យ ការរក្សាឯកជនភាពនិងការសម្ងាត់ និងការមិនរើសអើង
- បង្កើនលទ្ធភាពងាយស្រួលដល់ជនរងគ្រោះក្នុងការទទួលបានសេវាចម្រុះសំខាន់ៗនៅកន្លែងតែមួយនិងទទួលបានសេវាដោយឥតគិតថ្លៃ
- តម្រង់ទិសក្នុងការរៀបចំកន្លែងផ្តល់សេវាចម្រុះជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមបទដ្ឋានសមស្រប និងឆ្លើយតបចំពោះតម្រូវការរបស់ជនរងគ្រោះដែលមានអត្តសញ្ញាណសង្គមខុសៗគ្នា ដោយគោរពសេចក្តីថ្លៃថ្នូរ និងគ្មានការរើសអើង
- បង្កើនការសហការ ការសម្របសម្រួលប្រកបដោយប្រសិទ្ធិភាព ក្នុងដំណើការកន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះជនរគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ
- លើកកម្ពស់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ។

## ២. ស្ថានភាពអំពើហិង្សាលើស្ត្រីនៅប្រទេសកម្ពុជា

អំពើហិង្សាលើស្ត្រី គឺជាអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលបង្ក ឬទំនងជាបង្កឱ្យមានគ្រោះថ្នាក់ ឬការឈឺចាប់ផ្នែករាងកាយ ផ្លូវភេទ ឬផ្លូវចិត្ត ចំពោះស្ត្រី រួមទាំងការគំរាមប្រព្រឹត្តទង្វើទាំងនោះ ការបង្ខិតបង្ខំ ឬការដកហូតសេរីភាពតាមទំនើងចិត្ត មិនថាកើតមានឡើងនៅទីសាធារណៈ ឬក្នុងជីវិតឯកជន។ នៅទូទាំងសកលលោកមានការទទួលស្គាល់ថា **វិសមភាពយេនឌ័រ និងការរើសអើងគឺជាបុព្វហេតុឫសគល់**នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ[1] ។

ទម្រង់ទូទៅនៃអំពើហិង្សាទាក់ទងនឹងយេនឌ័ររួមមានអំពើហិង្សាផ្លូវភេទ (ការរំលោភសេពសន្ថវៈ ការប៉ុនប៉ងរំលោភ ការប៉ះពាល់ដែលគេមិនចង់បាន ការកេងប្រវ័ញ្ចផ្លូវភេទ និងការបៀតបៀនផ្លូវភេទ) អំពើហិង្សា ប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល (ហៅម្យ៉ាងទៀតថាអំពើហិង្សាក្នុងគ្រួសារ រួមមានដូចជាការរំលោភបំពានផ្នែក រាងកាយ ផ្លូវចិត្ត ផ្លូវភេទ និងផ្នែកសេដ្ឋកិច្ច) និងការអនុវត្តបែបវប្បធម៌ប្រពៃណីប្រកបដោយគ្រោះថ្នាក់ រួមទាំងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអាពាហ៍ពិពាហ៍នៅវ័យក្មេងផងដែរ។

[1] គេហទំព័ររបស់ UN Women (២០១៨) *Ending Violence Against Women* ថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០១៨។ http://www.unwomen.org/en/what-we-do/ending-violence-against-women.

ស្ត្រីជួបបទពិសោធន៍អំពើហិង្សានៅក្នុងផ្ទះ នៅកន្លែងធ្វើការ និងនៅក្នុងសហគមន៍។ ប្រភេទអំពើហិង្សាលើស្ត្រី ដែលច្រើនកើតមានបំផុតនៅក្នុងប្រទេសកម្ពុជាគឺអំពើហិង្សាក្នុងគ្រួសារ (អំពើហិង្សាដោយដៃគូស្និទ្ធស្នាល)[2] និងអំពើហិង្សាផ្លូវភេទ។

អំពើហិង្សាទាក់ទងនឹងយេនឌ័រគ្រប់ទម្រង់ទាំងអស់សុទ្ធតែមានផលវិបាកដ៏ធំធេងទាំងផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ចំពោះជនរងគ្រោះដោយសារទង្វើទាំងនេះ ជារឿយៗអ្នកទាំងនេះត្រូវបានហៅថា "ជនរងគ្រោះ"។ អំពើហិង្សាទាក់ទងនឹងយេនឌ័រ មានសិទ្ធិទទួលបានការថែទាំ ការគាំទ្រ និងសេវាចាំបាច់ប្រកបដោយគុណភាព ដើម្បីជួយពួកគេឱ្យបានសះជាឡើងវិញ។

## អំពើហិង្សាក្នុងគ្រួសារ

អំពើហិង្សាក្នុងគ្រួសារ និង/ឬអំពើហិង្សាប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល គឺជាទម្រង់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលកើតមានច្រើនជាងគេ ហើយជាកង្វល់ដ៏ធ្ងន់ធ្ងរក្នុងពិភពលោកក៏ដូចជាក្នុងសង្គមកម្ពុជា។ យោងតាមការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ ២០២១-២០២២ បង្ហាញឱ្យឃើញថា៖

- ២១%នៃស្ត្រីកម្ពុជាបានរាយការណ៍ថា ពួកគេធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត ឬផ្នែកសេដ្ឋកិច្ច ដែលប្រព្រឹត្តដោយដៃគូសិទ្ធស្នាលនៅក្នុងជីវិតរបស់ខ្លួន។
- ទូទៅ១៣%នៃស្ត្រីអាយុ១៥-៤៩ឆ្នាំដែលធ្លាប់រៀបការបានរាយការណ៍ថាធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ ផ្លូវភេទពីដៃគូស្និទ្ធស្នាល។
- ភាគរយស្ត្រីអាយុពី១៥-៤៩ឆ្នាំ ធ្លាប់រងអំពើហិង្សាលើរាងកាយពីដៃគូស្និទ្ធស្នាល មាន ៨,៧% ។
- ស្ត្រីប្រមាណ ៣ នាក់ក្នុងចំណោម ១០ នាក់ធ្លាប់បានស្វែងរកជំនួយដើម្បីបញ្ឈប់អំពើហិង្សាដែលខ្លួនធ្លាប់ទទួលរង ហើយមានតែ៣០.៩% ប៉ុណ្ណោះដែលរាយការណ៍ថាបានស្វែងរកជំនួយពីសេវាផ្លូវការ[3]។

## ការរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទ

ការរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទគឺជាកង្វល់មួយផងដែរក្នុងប្រទេសកម្ពុជា។ យោងទៅលើទិន្នន័យនៃការរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទបង្ហាញថា៖

---

[2] អំពើហឹង្សាប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល (IPV) សំដៅទៅលើអាកប្បកិរិយាទាំងឡាយណានៅក្នុងទំនាក់ទំនងដៃគូស្និទ្ធស្នាលដែលបង្កឱ្យមានគ្រោះថ្នាក់ផ្លូវកាយ ផ្លូវចិត្ត ឬផ្លូវភេទចំពោះអ្នកដែលស្ថិតក្នុងទំនាក់ទំនងនោះ។ អំពើហិង្សានេះរួមមានទាំងអំពើហិង្សាផ្លូវកាយ អំពើហិង្សាផ្លូវភេទ អំពើហិង្សាផ្លូវចិត្ត រួមទាំងអាកប្បកិរិយាត្រួតត្រា និងអំពើហិង្សាផ្នែកសេដ្ឋកិច្ច។ អំពើហិង្សាក្នុងគ្រួសារគឺស្រដៀងគ្នាជាមួយពាក្យអំពើហិង្សាប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលដែរ ដោយពាក្យនេះសំដៅលើអំពើហិង្សាស្ថិតក្នុងទំនាក់ទំនងដៃគូស្និទ្ធស្នាល។ ក្នុងប្រទេសកម្ពុជា នៅក្នុងច្បាប់ស្តីពីការបង្ការអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ (២០០៥) អំពើហិង្សាក្នុងគ្រួសារត្រូវបានកំណត់និយមន័យថា ជាអំពើហិង្សារវាងប្តី ឬប្រពន្ធ ទៅលើកូនក្នុងបន្ទុក ឬជនដែលរស់នៅក្នុងផ្ទះជាមួយគ្នា និងដែលជាអ្នកស្ថិតក្នុងបន្ទុករបស់គ្រួសារ។ និយមន័យបែបចង្អៀតនេះ បានផ្តល់លទ្ធផលធ្វើឱ្យមានដែនកំណត់ ឬភាពខុសប្លែកមួយចំនួននៅក្នុងទិន្នន័យ ដែលនឹងត្រូវកំណត់ឃើញនៅពេលមានភាពពាក់ព័ន្ធ។

[3] ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ ២០២១-២០២២

- ៣%នៃស្ត្រីអាយុ១៥-៤៩ឆ្នាំធ្លាប់ទទួលរងអំពើហិង្សាផ្លូវភេទ យ៉ាងហោចណាស់ម្តងក្នុងជីវិតរបស់ខ្លួន[4]
- ៥%នៃស្ត្រីអាយុ១៥-៤៩ ឆ្នាំបានរាយការណ៍ថាធ្លាប់ជួបបទពិសោធន៍ការបៀតបៀនផ្លូវភេទ យ៉ាងហោចណាស់មួយទម្រង់នៅក្នុងជីវិតរបស់ខ្លួន[5] ។
- ៤%នៃស្ត្រីអាយុ១៥-៤៩ឆ្នាំ បានរាយការណ៍ថាធ្លាប់ទទួលរងការរំលោភបំពានផ្លូវភេទយ៉ាងហោចណាស់ម្តងមុនអាយុ ១៨ ឆ្នាំ[6] ។
- ការរំលោភបំពានផ្លូវភេទប្រព្រឹត្តដោយជនប្រព្រឹត្តច្រើនជាងម្នាក់ ពុំមែនជារឿងមិនសូវកើតមាននោះឡើយ។ក្នុងចំណោមស្ត្រីនិងបុរសដែលមានអាយុ១៨-២៤ឆ្នាំ ស្ត្រីច្រើនជាងម្នាក់ក្នុងចំណោម ១០នាក់ និងបុរសលើសពីមួយភាគបួន បានរាយការណ៍ថា ករណីកើតហេតុដំបូងបំផុតនៃការរំលោភបំពានផ្លូវភេទក្នុងវ័យក្មេងត្រូវបានប្រព្រឹត្តដោយមនុស្សច្រើនជាងម្នាក់។ ក្នុងចំណោមអ្នកមានអាយុ១៣ ដល់ ១៧ឆ្នាំ ស្ត្រីម្នាក់ក្នុងចំណោម៨នាក់ និងបុរសម្នាក់ក្នុងចំណោម៨នាក់ បានរាយការណ៍ថាមានជនសង្ស័យច្រើនជាងម្នាក់ក្នុងករណីកើតហេតុដំបូងនៃការរំលោភបំពានផ្លូវភេទ[7]។
- បទពិសោធន៍នៃអំពើហិង្សា មានភាពខុសគ្នាក្នុងចំណោមក្រុមស្ត្រីផ្សេងៗគ្នា។ ស្ត្រីវ័យចំណាស់ទំនងជាធ្លាប់ទទួលរងអំពើហិង្សា (អាយុពី៣០-៤៩ ឆ្នាំ) ក៏ដូចជាស្ត្រីនៅតាមជនបទ(២៣% ធៀបនឹង១៧ % នៅក្នុងតំបន់ទីក្រុង) ស្ត្រីក្រីក្រនិងអ្នកដែលមានការអប់រំទាបជាង។ ២% នៃស្ត្រីមានពិការភាពទំនង ជាទទួលរងអំពើហិង្សាពីដៃគូស្និទ្ធស្នាលជាងជាស្ត្រីមិនមានពិការភាពនិងទំនងជាទទួលរងអំពើហិង្សាផ្លូវកាយ ឬផ្លូវភេទច្រើនជាងស្ត្រីមិនមានពិការភាពដល់ទៅ២ដង។ ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលមានពិការភាព មានស្វ័យភាពផ្នែកហិរញ្ញវត្ថុ ឬរបរវន្តតិចជាងស្ត្រីមិនមានពិការភាពក្នុងការទទួលបានសេវានានា ជាពិសេសនៅតំបន់ជនបទ។ ស្ត្រីជនជាតិដើមភាគតិចក៏ប្រឈមមុខនឹងអំពីហិង្សាពីដៃគូស្និទ្ធស្នាល ការបៀតបៀន និងការរៀបការមុនអាយុយ៉ាងច្រើនផងដែរ និងជួបប្រទះឧបសគ្គច្រើនកាន់តែថែមទៀតក្នុងការទៅរកសេវាអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងឧបសគ្គភាសា និងវប្បធម៌ និងការប្រើប្រាស់វិធីសាស្ត្រតាមប្រពៃណីក្នុងការដោះស្រាយករណីហិង្សាទាក់ទងនឹងយេនឌ័រ។ យោងតាមការសិក្សាមួយចំនួនក្រុមអ្នកស្រឡាញ់ភេទដូចគ្នា (LGBTI) ទំនងជាទទួលរងអំពើហិង្សាផ្លូវភេទ និងផ្លូវកាយច្រើនជាងគេ និងទទួលរងការបំភិតបំភ័យ និងការរើសអើងក្នុងទម្រង់ជាច្រើន ។
- អត្រាប្រេវ៉ាឡង់នៅក្នុង CDHS មានការប្រែប្រួលយ៉ាងខ្លាំងនៅតាមខេត្តនានា ដោយក្នុងនោះខេត្តកោះកុងមានអត្រាទាបជាងគេបំផុត(៦%) និងខេត្តមណ្ឌលគិរីមានអត្រាខ្ពស់ជាងគេបំផុត(៤៥%)។

---

[4] ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ ២០២១-២០២២

[5] ក្រសួងកិច្ចការនារី (២០១៥) *ការសិក្សាថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធន៍ជីវិតរបស់ស្ត្រីក្នុងប្រទេសកម្ពុជា* រាជធានីភ្នំពេញ

[6] ក្រសួងកិច្ចការនារី (២០១៤) *ការសិក្សាអង្កេតស្តីពីអំពើហិង្សាលើកុមាររបស់ក្នុងប្រទេសកម្ពុជា* រាជធានីភ្នំពេញ

[7] ក្រសួងកិច្ចការនារី (២០១៤) *ការសិក្សាអង្កេតស្តីពីអំពើហិង្សាលើកុមាររបស់ក្នុងប្រទេសកម្ពុជា* រាជធានីភ្នំពេញ

តារាងខាងក្រោម បង្ហាញពីទិន្នន័យប្រេវ៉ាឡង់ឆ្នាំ ២០២១-២០២២ និងឆ្នាំ២០១៤ សម្រាប់ខេត្តគោលដៅរបស់កម្មវិធី ACCESS 2 ។ តារាងនេះបង្ហាញពីការថយចុះនៃអត្រាប្រេវ៉ាឡង់នៅក្នុងខេត្តកំពង់ស្ពឺ រាជធានីភ្នំពេញ និងកំពង់ចាម ដោយខេត្តកំពង់ចាមមានការថយចុះខ្លាំងជាងគេបំផុតគឺពី ៣៣,២%ក្នុងឆ្នាំ២០១៤ មក ១២% នៅឆ្នាំ២០២១-២០២២។ ទាំងខេត្តសៀមរាប និងរតនគិរីមានការកើនឡើងនូវអត្រាប្រេវ៉ាឡង់ ដោយក្នុងនោះខេត្តរតនគិរីមានការកើនឡើងជិតពីរដង ។

ម្យ៉ាងវិញទៀត ក៏មានការទទួលស្គាល់ថា ក្រុមស្ត្រីផ្សេងៗទៀត រងគ្រោះពីការរើសអើង និងវិសមភាពយេនឌ័រច្រើនទម្រង់ដែលធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះដោយអំពើហិង្សា។ បទដ្ឋានសង្គម ការមាក់ងាយ និងការរើសអើងអាចបង្កើនហានិភ័យនៃអំពើហិង្សាឬបង្កឱ្យមានបញ្ហាប្រឈមក្នុងការទទួលបានកិច្ចការពារ និង ការទទួលសេវារបស់ពួកគាត់។ ជនរងគ្រោះទាំងនេះរួមមាន ស្ត្រីមានពិការភាព ស្ត្រីរស់នៅជាមួយជំងឺអេដស៍ ស្ត្រីស្រឡាញ់ភេទដូចគ្នា បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្លែងភេទ(LGBT) ស្ត្រីវ័យចាស់ ស្ត្រីជាកម្មករនិយោជិតទេសន្តប្រវេសន៍ ស្ត្រីបម្រើសេវាកម្សាន្ត កម្មការិនីរោងចក្រ និងកម្មការិនីដទៃទៀត ស្ត្រីប្រើប្រាស់គ្រឿងញៀន ឬស្ត្រីមានដៃគូជាអ្នកប្រើប្រាស់គ្រឿងញៀន ស្ត្រីជាប់ពន្ធនាគារ ស្ត្រីជនជាតិដើមភាគតិច និងស្ត្រីមកពីក្រុមសាសនាភាគតិច ឬជនជាតិភាគតិច។

### ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ

អំពើហិង្សាទាក់ទងនឹងយេនឌ័រកើតឡើងគ្រប់ទីកន្លែងដោយមិនប្រកាន់ភេទ អត្តសញ្ញាណយេនឌ័រ និន្នាការភេទ ជាតិសាសន៍ ឬវណ្ណៈនោះឡើយ។ តាមការសិក្សាជាច្រើន បង្ហាញថា ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ**ភាគច្រើនគឺជាស្ត្រីនិងក្មេងស្រី** ហើយបុរសនិងក្មេងប្រុស ស្ត្រីស្រឡាញ់ភេទដូចគ្នា បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្លែងភេទ (LGBT) ក៏ធ្លាប់ទទួលបទពិសោធន៍រងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រនេះផងដែរ។

## ៣. សេវាឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ

សេវាចាំបាច់សម្រាប់ជនរងគ្រោះដោយអំពើហិង្សារួមមាន សេវាសុខាភិបាល សេវានគរបាលនិងយុត្តិធម៌ សេវាជម្រកសុវត្ថិភាព សេវាសង្គមដទៃទៀត។ ជនរងគ្រោះដោយអំពើហិង្សាតែងតែមានតម្រូវការសេវាខុសៗគ្នា អាស្រ័យលើប្រភេទនៃការរំលោភបំពាននីមួយៗក៏ដូចជាស្ថានភាពជាក់ស្តែងរបស់ជនរងគ្រោះ។ ប្រភេទសេវាដែលជនរងគ្រោះត្រូវការមានដូចជា សេវាសុខភាព សេវានគរបាលនិងយុត្តិធម៌ និងកន្លែងស្នាក់នៅដែលមានសុវត្ថិភាព ព្រមទាំងសេវាសង្គមដទៃទៀតដូចជាការប្រឹក្សាផ្លូវចិត្ត ឬការគាំទ្រដើម្បីពង្រឹងភាពអង់អាចផ្នែក សេដ្ឋកិច្ចជាដើម។

រូបភាពខាងក្រោមបង្ហាញអំពីសេវាចាំបាច់សំខាន់ៗមួយចំនួន ដែលជនរងគ្រោះអាចត្រូវការ។ អ្នកផ្តល់សេវាគួរសិក្សាអំពីសេវានីមួយៗនៅក្នុងសហគមន៍របស់ខ្លួនសម្រាប់ផ្តល់ជាជម្រើសដល់ជនរងគ្រោះ។

- ការថែទាំ និងព្យាបាលបួសស្នាមបន្ទាន់
- ការថែទាំសុខភាពបន្ទាន់សម្រាប់ករណីរំលោភសេពសន្ទវៈ (ថ្នាំការពារការឆ្លងមេរោគអេដស៍ និងការពារកំណើតបន្ទាន់ឱ្យបានមុន ៧២ម៉ោង)
- ការពិនិត្យកោសល្យវិច័យសម្រាប់អំពើហិង្សាផ្លូវភេទ




- ទទួល និងផ្តល់ព័ត៌មានផ្នែកច្បាប់ និងសេវាមេធាវី
- ផ្តល់កិច្ចការពារ និងការអន្តរាគមន៍ក្នុងករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ
- ដំណើរការនីតិវិធី
- ដីកាការពារ

- ការស្នាក់នៅបណ្តោះអាសន្នជាមួយសាច់ញាតិ
- ការស្នាក់នៅបណ្តោះអាសន្នជាមួយសមាជិកសហគមន៍
- ការស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាព

- ការប្រឹក្សាយោបល់ផ្លូវចិត្តកម្រិតមូលដ្ឋាន និងកម្រិត ឯកទេស
- ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ច
- សេវាបកប្រែភាសា និងភាសាសញ្ញា

ស្ត្រីភាគច្រើនដែលរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រពុំសូវស្វែងរកជំនួយពីសេវាផ្លូវច្បាប់ទេ ។ ឥរិយាបថបែបប្រពៃណីដែលស្តីបន្ទោសស្ត្រី ថ្លៃចំណាយ និងមានកត្តាដទៃទៀត គឺជាឧបសគ្គរារាំងស្ត្រីមិនឱ្យស្វែងរកជំនួយ ។

ដើម្បីលើកកម្ពស់ការឆ្លើយតបគុណភាពសេវា និងការសម្របសម្រួលសេវាជាពហុវិស័យសម្រាប់ជនរងគ្រោះ បានចែងក្នុង *ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីឆ្នាំ២០១៩-២០២៣* អំពីអាទិភាពសម្រាប់ការទប់ស្កាត់ ការសម្របសម្រួលកាន់តែប្រសើរ កិច្ចការពារផ្នែកច្បាប់ និងសេវាពហុវិស័យ រួមទាំងយន្តការសម្របសម្រួលពហុវិស័យ ឬ**ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ** (GBV Working Goup)។

## ៤. កន្លែងផ្តល់សេវាចម្រុះ

កន្លែងផ្តល់សេវាចម្រុះជាកន្លែងសម្របសម្រួលនិងផ្តល់សេវាចម្រុះដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងកន្លែងតែមួយ ដែលមានសេវាសុខាភិបាល ជំនួយផ្នែកច្បាប់ ការប្រឹក្សាផ្លូវចិត្ត និងសេវាសង្គមផ្សេងៗ រួមទាំងផ្តល់ជម្រកសុវត្ថិភាព។ កន្លែងផ្តល់សេវាចម្រុះត្រូវរៀបចំដោយផ្តោតលើជនរងគ្រោះ ដែលទាមទារនូវដំណើរការអន្តរកម្ម ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ជនរងគ្រោះ។

កន្លែងផ្តល់សេវាចម្រុះស្ថិតក្នុងទីតាំងមន្ទីរពេទ្យរាជធានី ខេត្ត មន្ទីរពេទ្យតំបន់ មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ ហើយត្រូវមានគោលការណ៍សំខាន់ៗ សម្រាប់អ្នកផ្តល់សេវាដោយផ្តោតលើសិទ្ធិជនរងគ្រោះជាចម្បង ដូចជាការគោរពអភិក្រមសិទ្ធិមនុស្ស ការធានាសុវត្ថិភាព ការពង្រឹងភាពអង់អាចឥរិយាបថមិនស្តីបន្ទោស និងមិនធ្វើការវិនិច្ឆ័យ ការរក្សាឯកជនភាពនិងការសម្ងាត់ និងការមិនរើសអើង នឹងត្រូវបានលើកកម្ពស់ ហើយត្រូវអនុវត្តដោយអ្នកផ្តល់សេវាជាចាំបាច់។

កន្លែងផ្តល់សេវាចម្រុះត្រូវផ្តល់សេវា២៤ម៉ោង ជារៀងរាល់ថ្ងៃសម្រាប់ជនរងគ្រោះដោយអំពើហិង្សា ហើយត្រូវមានបុគ្គលិកប្រចាំការនិងមានសៀវភៅព័ត៌មានអំពីសេវាសម្រាប់ជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ផែនទីសេវា និងសៀវភៅសម្រាប់ទំនាក់ទំនងអ្នកផ្តល់សេវាដទៃទៀតក្នុងករណីចាំបាច់។

## ៥. វិសាលភាព និងដែនកំណត់

គោលការណ៍ណែនាំស្តីពីការរៀបចំកន្លែងផ្តល់សេវាចម្រុះ គឺដើម្បីផ្តល់ការណែនាំអំពីដំណើរការនៃការរៀបចំ និងការអនុវត្តនៅកន្លែងផ្តល់សេវាចម្រុះ មាននៅតែថ្នាក់រាជធានី ខេត្ត ក្រុង ស្រុកខណ្ឌ ប៉ុណ្ណោះ ជាពិសេសផ្តោតលើការផ្តល់និងទទួលសេវាទាក់ទងនឹងករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រប្រកបដោយបរិយាបន្ន នៅតាមទីតាំង មន្ទីរពេទ្យរាជធានី ខេត្ត មន្ទីរពេទ្យតំបន់ មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ។

ការផ្តល់និងទទួលសេវានឹងត្រូវប្រព្រឹត្តទៅតាមគោលការណ៍ស្ម័គ្រចិត្តនិងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ ព្រមទាំងក្រមសីលធម៌របស់អ្នកផ្តល់សេវា។

## ៦.នីតិវិធីក្នុងការរៀបចំកន្លែងផ្តល់សេវាចម្រុះ

ក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាល សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រៀបចំកន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រគ្រប់ទម្រង់ នៅតាម មន្ទីរពេទ្យរាជធានី ខេត្ត មន្ទីរពេទ្យតំបន់ និងមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ ដើម្បីសម្រួលការផ្តល់សេវាផ្នែកច្បាប់ សេវាសង្គម សេវាសុខាភិបាលនិងសេវាផ្សេងទៀតជូនជនរងគ្រោះ។ ដំណើរការនៃការរៀបចំកន្លែងផ្តល់សេវាចម្រុះមានដូចខាងក្រោម៖




### ៦.១ ដំណាក់កាលទី១៖ ការរៀបចំបង្កើតក្រុមការងារថ្នាក់ជាតិ

យោងលើឯកសារគតិយុត្តពាក់ព័ន្ធ ក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាល ដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំ និងសម្របសម្រួលបង្កើតឱ្យមានក្រុមការងារថ្នាក់ជាតិ ដោយមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធដូចជា ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ស្ថាប័នតុលាការ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសង្គមស៊ីវិល។ សមាជិកក្រុមការងារត្រូវចូលរួមគាំទ្រដំណើរការរៀបចំបង្កើតកន្លែងផ្តល់សេវារហូតដល់ការផ្តល់សេវាជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រទៅតាមតួនាទីនិងភារកិច្ចរបស់ក្រសួងស្ថាប័ន។

ក្រុមការងារត្រូវរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ទៀងទាត់ ឬ ដើម្បីពិភាក្សាអំពីការរៀបចំបង្កើតកន្លែងផ្តល់សេវាចម្រុះ និងការផ្តល់សេវាចម្រុះប្រកបដោយប្រសិទ្ធភាព និងបរិយាបន្ន។

### ៦.២ ដំណាក់កាលទី ២៖ សិក្សា ប្រមូលព័ត៌មាន

ក្រសួងនិងមន្ទីរកិច្ចការនារី ដឹកនាំសម្របសម្រួលប្រមូលទិន្នន័យនិងព័ត៌មានស្តីពីស្ថានភាពអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមរាជធានី ខេត្ត ជាពិសេសទាក់ទងនឹងសេវាដែលជាតម្រូវការចាំបាច់ បញ្ហាប្រឈម និងដំណើរការនៃការដោះស្រាយករណីនីមួយៗរបស់ក្រសួង ស្ថាប័ននិងអាជ្ញាធរពាក់ព័ន្ធ ព្រមទាំងការអនុវត្តល្អ មេរៀននិងបទពិសោធន៍ទទួលបានអំពីបណ្តាប្រទេសផ្សេងៗទាក់ទងនឹងការអនុវត្តកន្លែងផ្តល់សេវាចម្រុះដែលទទួលបានជោគជ័យ។

ស្វែងយល់ពីកិច្ចសហការជាមួយអ្នកពាក់ព័ន្ធទាំងស្ថាប័នរដ្ឋាភិបាល និងអង្គការដៃគូក្នុងការចូលរួមទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ជាពិសេសកិច្ចសហការជាមួយមន្ទីរសុខាភិបាល និងមន្ទីរពេទ្យរាជធានី ខេត្ត មន្ទីរពេទ្យតំបន់។

រៀបចំទស្សនកិច្ចសិក្សាស្វែងយល់អំពីបទពិសោធន៍នៃការអនុវត្តល្អនៅតាមរាជធានី ខេត្ត និងតាមបណ្តាប្រទេសដែលអនុវត្តការងារបានជោគជ័យ។

រៀបចំរបាយការណ៍លទ្ធផលនៃការសិក្សាប្រមូលព័ត៌មាន ដើម្បីចែករំលែកជាមួយអ្នកពាក់ព័ន្ធនានា ។

## ៦.៣ ដំណាក់កាលទី ៣៖ ការពិគ្រោះយោបល់ និងការព្រមព្រៀងលើតួនាទីភារកិច្ចជាមួយអ្នកពាក់ព័ន្ធ ការទទួលខុសត្រូវរបស់ក្រុមការងារនៃក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាល៖

### ក្រុមការងារក្រសួងកិច្ចការនារី៖

ដឹកនាំនិងសម្របសម្រួលក្នុងការអញ្ជើញ ផ្តល់ព័ត៌មាន រៀបចំជារបាយការណ៍ និងចែករំលែកដល់អ្នកពាក់ព័ន្ធ។

### ក្រុមការងារក្រសួងសុខាភិបាល៖

ដឹកនាំនិងសម្របសម្រួលក្នុងការអញ្ជើញនិងផ្តល់ព័ត៌មានដល់មន្ទីរសុខាភិបាល និងប្រធានមន្ទីរពេទ្យក្នុងការចុះស្វែងយល់ពីស្ថានភាពរបស់ក្រុមការងារថ្នាក់ជាតិ និងទីតាំងសម្រាប់រៀបចំដំណើរការនៃកន្លែងផ្តល់សេវាចម្រុះដំណើរការដោយរលូន។

### ការចុះស្វែងយល់ពីទីតាំង៖

ក្រុមការងារត្រូវរៀបចំកិច្ចប្រជុំជាមួយអ្នកពាក់ព័ន្ធដូចជាប្រធានមន្ទីរសុខាភិបាល ប្រធានមន្ទីរពេទ្យ និងក្រុមការងារដើម្បីបង្ហាញអំពីគោលបំណងនៃការបង្កើតកន្លែងផ្តល់សេវាចម្រុះក្នុងមន្ទីរពេទ្យ ឯកសារយោងពាក់ព័ន្ធមួយចំនួន ធនធានដែលត្រូវការ និងដំណើរការទូទៅនៃការបង្កើតឱ្យមានកន្លែងនេះ។

ក្រុមការងារថ្នាក់ជាតិត្រូវចុះពិនិត្យទីតាំងផ្ទាល់នៅតាមមន្ទីរពេទ្យដោយធានាថា កន្លែងផ្តល់សេវាចម្រុះគ្មានការរំខាន មានផាសុកភាព មានសុវត្ថិភាព មិនមានមនុស្សចេញចូល (មានតែអ្នកផ្តល់សេវា និងជនរងគ្រោះឬសាច់ញាតិជនរងគ្រោះ) និងមិនត្រូវដាក់ស្លាកសញ្ញាថាជាកន្លែងផ្តល់សេវាចម្រុះដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដើម្បីរក្សាឯកជនភាពនិងការសម្ងាត់។

### ការពិគ្រោះយោបល់ និងការព្រមព្រៀងលើតួនាទីភារកិច្ចជាមួយអ្នកពាក់ព័ន្ធ

ក្រុមការងារត្រូវរៀបចំសិក្ខាសាលាពិគ្រោះយោបល់អំពីដំណើរការនៃការរៀបចំ និងនិយាមប្រតិបត្តិសម្រាប់ការប្រព្រឹត្តទៅនៃកន្លែងផ្តល់សេវាចម្រុះ រួមទាំងការគ្រប់គ្រងករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ

ជាមួយអ្នកពាក់ព័ន្ធ ដែលជាសមាជិកក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដោយមានការសម្របសម្រួលពីក្រុមការងារក្រសួងកិច្ចការនារីនិងក្រសួងសុខាភិបាល ដើម្បីបង្ហាញពីគោលបំណងនៃការរៀបចំកន្លែងផ្តល់សេវាចម្រុះ ធនធានដែលត្រូវការ ការបែងចែកតួនាទី ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ លំហូរនៃការបញ្ជូនជនរងគ្រោះ និងដំណើរការទូទៅនៃការរៀបចំកន្លែងផ្តល់សេវាចម្រុះ។ មន្ទីរកិច្ចការនារីជាសមាជិកអចិន្ត្រៃយ៍ត្រូវរៀបចំនិងចងក្រងរបាយការណ៍រាល់ពេលសិក្ខាសាលាឬកិច្ចប្រជុំ និងធ្វើការចែកជូនដល់ក្រុមការងារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ៦.៤ ដំណាក់កាលទី ៤៖ ការដាក់ឱ្យដំណើរការកន្លែងផ្តល់សេវាចម្រុះជាផ្លូវការ

### ការរៀបចំ ធនធាន ហេដ្ឋារចនាសម្ព័ន្ធ សម្ភារបរិក្ខា និងការគាំទ្រផ្នែករដ្ឋបាល

**ធនធានបុគ្គលិក៖**

កន្លែងផ្តល់សេវាចម្រុះ ត្រូវមានបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាល មានជំនាញ និងការទទួលខុសត្រូវក្នុងការឆ្លើយតបចំពោះអំពើហិង្សា របៀបនៃការគ្រប់គ្រង និងការបញ្ជូនករណីឱ្យបានទាន់ពេល។ល។

កន្លែងផ្តល់សេវាចម្រុះត្រូវមានបុគ្គលិកប្រចាំការជានិច្ច ដើម្បីត្រៀមទទួលជនរងគ្រោះ សម្របសម្រួល ក្នុងការផ្តល់សេវាទាំងផ្នែកខាងក្នុង និងការបញ្ជូនជនរងគ្រោះ។

**ហេដ្ឋារចនាសម្ព័ន្ធកន្លែងផ្តល់សេវាចម្រុះ៖**

- **បន្ទប់ត្រូវរក្សាឯកជនភាពនិងសុវត្ថិភាពដោយអាច៖**
  - សម្រាកបណ្តោះអាសន្ន ស្នាក់នៅបានត្រឹម២៤ម៉ោង
  - ការពារសំឡេងមិនឱ្យមានការរំខានពីខាងក្រៅ សំឡេងដែលអាចរំខានការសម្ភាសន៍ នឹងធ្វើឱ្យអ្នកសម្ភាសន៍ និងជនរងគ្រោះមានអារម្មណ៍ថាមិនសូវមានសុវត្ថិភាព និងផាសុកភាព
  - ការពារសំឡេងមិនឱ្យចេញពីខាងក្នុងមកក្រៅ ដែលធ្វើឱ្យព័ត៌មានរបស់ជនរងគ្រោះ ឬ ការសម្ភាសន៍មិនមានសុវត្ថិភាព។ ទ្វារនិងបង្អួចត្រូវបិទជិត និងមានការការពារសំឡេងមិនឱ្យឮការសន្ទនាចេញមកក្រៅ
  - ត្រូវមានស្លាកអំពី "**ហាមចូលបន្ទប់មានភ្ញៀវ**" សម្រាប់ព្យួរដាក់នៅនឹងទ្វារបន្ទប់ផ្តល់សេវាចម្រុះ ពេលដែលកំពុងមានជនរងគ្រោះនៅខាងក្នុង ដើម្បីហាមអ្នកដទៃចូល។




- **ពន្លឺភ្លើងបំភ្លឺក្នុងបន្ទប់៖** បន្ទប់គួរប្រើភ្លើងបំភ្លឺជួយឱ្យជនរងគ្រោះមានអារម្មណ៍វិជ្ជមាន(ពន្លឺពណ៌ស)។ បន្ទប់គួរមានបង្អួចកញ្ចក់ដើម្បីទទួលពន្លឺធម្មជាតិ និងការមើលឃើញទិដ្ឋភាពនៅខាងក្រៅ (តែអ្នកខាងក្រៅមិនអាចមើលខាងក្នុងឃើញ)ដើម្បីជួយឱ្យបរិកាសនៃការសន្ទនាមានភាពស្រស់ស្រាយ។
- **ម៉ាស៊ីនត្រជាក់ កង្ហារ៖** បន្ទប់គួរតំឡើងម៉ាស៊ីនត្រជាក់ ឬ កង្ហារ។

- **បន្ទប់ទឹក៖** គួរមានបន្ទប់ទឹក និងសម្ភារៈប្រើប្រាស់ក្នុងបន្ទប់ទឹក។
- **ការភ្ជាប់ជនរងគ្រោះទៅសេវាសុខភាពដទៃនានានៅក្នុងមូលដ្ឋានសុខាភិបាល៖** ជនរងគ្រោះមានលទ្ធភាពងាយស្រួល ត្រូវបានភ្ជាប់ទៅសេវាសុខភាពដទៃនានានៅក្នុងមូលដ្ឋានសុខាភិបាលដូចជាសេវាផ្តល់ថ្នាំការពារការឆ្លងមេរោគអេដស៍ ជំងឺកាមរោគ សេវាផ្តល់ថ្នាំបង្ការកំណើតបន្ទាន់ បន្ទប់ពិគ្រោះជំងឺ បន្ទាប់ពិនិត្យធ្វើកោសលវិច័យ សេវាថៃទាំដទៃទៀត។ល។
- **ការបញ្ជូនជនរងគ្រោះទៅរកសេវាដទៃទៀត៖** ជនរងគ្រោះមានលទ្ធភាពងាយស្រួល ត្រូវបានភ្ជាប់ទៅសេវានគរបាលយុត្តិធម៌និងប្រព័ន្ធតុលាការ និងសេវាសង្គមដទៃទៀត តាមរយៈកិច្ចសម្របសម្រួលពីមន្ទីរកិច្ចការនារី។
- **កុមារមេត្រី៖** កន្លែងផ្តល់សេវាចម្រុះ គួរមានកន្លែងលេងសម្រាប់កុមារ ក្នុងករណីជនរងគ្រោះមានកូនតូចមកជាមួយ ឬជនរងគ្រោះជាកុមារ។ កន្លែងលេងសម្រាប់កុមារ គួរតែនៅក្បែរបន្ទប់សម្ភាសន៍ជាមួយជនរងគ្រោះដែលកុមារ (កូន) អាចមើលឃើញម្តាយ និងលេងនៅកន្លែងនោះបាន។ ប្រសិនបើជនរងគ្រោះមានកូនតូចមកជាមួយ កន្លែងផ្តល់សេវាចម្រុះគួរមានបុគ្គលិកម្នាក់នៅជាមួយកុមារនោះពេលដែលជនរងគ្រោះកំពុងជួបជាមួយអ្នកប្រឹក្សាឬអ្នកផ្តល់សេវា។

  **ឧបករណ៍សម្រាប់កន្លែងលេងរបស់កុមារ៖**
  - សៀវភៅ និងផ្ទាំងរូបភាពអប់រំ
  - សម្ភារសម្រាប់កុមារ
  - ទូរទស្សន៍ដែលមានការបង្ហាញតុក្កតា
    (ភ្ជាប់ជាមួយបញ្ជីសម្ភារជាឯកសារ)

## សម្ភារបរិក្ខារឬសង្ហារឹម នៅកន្លែងផ្តល់សេវាចម្រុះ

- ផ្ទាំងគំនូរឬរូបភាព៖ នៅក្នុងបន្ទប់គួរមានផ្ទាំងគំនូរឬរូបភាពនានា សម្រាប់ការអប់រំ ការលើកទឹកចិត្តជនរងគ្រោះ សារគន្លឹះនានាដែលធ្វើឱ្យជនរងគ្រោះជឿជាក់លើអ្នកផ្តល់សេវានៅកន្លែងផ្តល់សេវាចម្រុះនិង ព័ត៌មានអំពីសេវា។
- ធ្នើរឬទូរដាក់ឯកសារ៖ ធ្នើរសម្រាប់ដាក់តាំងខិត្តប័ណ្ណព័ត៌មាន កូនសៀវភៅព័ត៌មានអំពីសេវាឯកសារណែនាំផ្សេងៗ សម្ភារពាក់ព័ន្ធ ទូរទុកដាក់ឯកសារកត់ត្រាចំនួនករណីជនរងគ្រោះនិងឯកសារសំខាន់ៗផ្សេងៗទៀតត្រូវចាក់សោរ រួមទាំងការកត់ត្រាឬបញ្ចូលទិន្នន័យ ដោយរក្សាការសម្ងាត់។
- បរិក្ខារពេទ្យចាំបាច់៖ គ្រែពេទ្យ បរិក្ខារពិនិត្យរោគ ។ល។
- សម្ភារៈសង្ហារឹម៖ កូនសាឡុងតូច សម្រាប់ជនរងគ្រោះអង្គុយរង់ចាំ តុការិយាល័យកៅអីអង្គុយ និងសម្ភារប្រើប្រាស់ចាំបាច់មួយចំនួន។
- ទឹកស្អាតសម្រាប់ពិសារ៖ មានទឹកគ្រប់គ្រាន់សម្រាប់ពិសាក្នុងបន្ទប់ផ្ទាល់។
- ឱសថ និងបរិក្ខារសំខាន់ៗចាំបាច់

### កន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ត្រូវមាន៖

- ថ្នាំឬសេវាសម្រាប់ជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រនិងផ្លូវភេទ(ការរងគ្រោះដោយអំពើរំលោភសេពសន្ថវៈ)៖
  - ថ្នាំបង្ការក្រោយប្រឈមនឹងការឆ្លងមេរោគអេដស៍(PEP) សម្រាប់ជនរងគ្រោះ (ទាំងបុរស ទាំងស្ត្រី)
  - ថ្នាំបង្ការកំណើតបន្ទាន់ (EC) សម្រាប់ស្ត្រីនិងក្មេងស្រី
  - ថ្នាំព្យាបាលជំងឺកាមរោគ (STI) សម្រាប់ជនរងគ្រោះ (ទាំងបុរស ទាំងស្ត្រី) ត្រូវត្រៀមទុកឱ្យបានគ្រប់គ្រាន់ជានិច្ច
- ថ្នាំ ឬសម្ភារសង្គ្រោះបឋម
- ឧបករណ៍ធ្វើតេស្តរកមេរោគអេដស៍ ដែលនៅមានសុពលភាព (ត្រូវតៀមទុកឱ្យបានគ្រប់គ្រាន់)
- ឧបករណ៍ធ្វើតេស្តផ្ទៃពោះ ដែលនៅមានសុពលភាព (ត្រូវតៀមទុកឱ្យបានគ្រប់គ្រាន់)

### ការគាំទ្រផ្នែករដ្ឋបាល

កន្លែងផ្តល់សេវាចម្រុះត្រូវមានសម្ភារ និងទូរតម្កល់ឯកសារសម្រាប់អ្នកផ្តល់សេវា ដូចខាងក្រោម៖

- កុំព្យូទ័រ សម្រាប់កត់ត្រា និងបញ្ចូលទិន្នន័យ
- ម៉ាស៊ីនព្រីន ស្កេននិងថតចម្លងឯកសារ
- សៀវភៅចុះបញ្ជីករណី
- សៀវភៅកត់ត្រាករណី (សង្ខេប)
- ទម្រង់បញ្ជូនទៅសេវាដទៃទៀត
- ទម្រង់សុំការយល់ព្រម (Consent Form)
- សៀវភៅផ្តល់ព័ត៌មានអំពីសេវាជួយជនរងគ្រោះ
- ឯកសារជំនួយស្មារតីសម្រាប់អ្នកផ្តល់សេវា៖
  - សៀវភៅព័ត៌មានអំពីសេវាសម្រាប់ជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមបញ្ចូលបញ្ជីសេវាតម្រូវការជនរងគ្រោះដែលមានពិការភាព ជនជាតិដើមភាគតិច។ល។
  - គោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រីនិងក្មេងស្រីដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ
  - ពិធីសារជាតិស្តីពី ការថែទាំសុខភាពស្ត្រីរងគ្រោះដោយអំពើហិង្សា
  - បទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ប្រឹក្សាជាមូលដ្ឋានដល់ស្ត្រីនិងក្មេងស្រីជាជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ

- បទដ្ឋានអប្បបរមានៃសេវាចាំបាច់សំខាន់ៗសម្រាប់ស្ត្រីនិងកុមារីដែលរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ
- ឯកសារពាក់ព័ន្ធផ្សេងទៀត។

## ៧ សមាសភាព តួនាទីនិងការទទួលខុសត្រូវរបស់អ្នកផ្តល់សេវានិងអ្នកពាក់ព័ន្ធ

សមាសភាព តួនាទីនិងការទទួលខុសត្រូវរបស់អ្នកផ្តល់សេវានិងអ្នកពាក់ព័ន្ធក្នុងការផ្តល់សេវាជួយជនរងគ្រោះ និងមានអ្នកសម្របសម្រួលក្នុងការផ្តល់ភាពងាយស្រួលសម្រាប់ឱ្យអ្នកផ្តល់សេវាពាក់ព័ន្ធចូលរួមក្នុងការផ្តល់សេវានៅកន្លែងផ្តល់សេវាចម្រុះមានដូចជា ៖

ថ្នាក់ជាតិ

- **ក្រុមការងារក្រសួងកិច្ចការនារី៖**
  សម្របសម្រួល និងដឹកនាំក្នុងការអញ្ជើញនិងផ្តល់ព័ត៌មាន រៀបចំរបាយការណ៍ និងចែករំលែកដល់អ្នកពាក់ព័ន្ធ ។
- **ក្រុមការងារក្រសួងសុខាភិបាល៖**
  សម្របសម្រួល និងដឹកនាំក្នុងការអញ្ជើញនិងផ្តល់ព័ត៌មានដល់មន្ទីរសុខាភិបាល និងប្រធានមន្ទីរពេទ្យ ដើម្បីឱ្យក្រុមការងារថ្នាក់ជាតិចុះស្វែងយល់ពីស្ថានភាព និងទីតាំងសម្រាប់រៀបចំបង្កើត និងដំណើរការកន្លែងផ្តល់សេវាចម្រុះដោយរលូន។
- **ក្រសួងមហាផ្ទៃ៖**
  ផ្តល់កិច្ចអន្តរាគមន៍ ចូលរួមគាំទ្រ និងជំរុញការអនុវត្តរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖**
  ចូលរួមគាំទ្រ និងជំរុញការផ្តល់សេវាដើម្បីស្តារនីតិសម្បទា និងធ្វើសមាហរណកម្មសម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

ថ្នាក់ក្រោមជាតិ

- **ប្រធានក្រុមការងារ GBV៖**
  ផ្តល់ការគាំទ្រ និងជំរុញគ្រប់ការងារអនុវត្តឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ។
- **មន្ទីរសុខាភិបាល៖**
  ជាសមាជិកអចិន្ត្រៃយ៍ ដឹកនាំ សហការ គាំទ្របច្ចេកទេស និងជំរុញការផ្តល់សេវាសុខភាព តាមតម្រូវការរបស់ជនរងគ្រោះ និងធ្វើរបាយការណ៍នានា។
- **មន្ទីរកិច្ចការនារី៖**
  ជាសមាជិកអចិន្ត្រៃយ៍ ធ្វើការផ្តល់សេវាប្រឹក្សាយោបល់ផ្លូវចិត្ត ផ្នែកច្បាប់ តាមជំនាញ និងធ្វើការសម្របសម្រួលស្វែងរកសេវាពាក់ព័ន្ធឱ្យជនរងគ្រោះទទួលបានសេវាចម្រុះ តាមតម្រូវការរបស់

ជនរងគ្រោះ និងធ្វើរបាយការណ៍ និងតាមដានស្ថានភាពជនរងគ្រោះ (សហការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា)។

មន្ទីរកិច្ចការនារី សហការជាមួយមន្ទីរសុខាភិបាលរាជធានី ខេត្តដើរតួនាទីសំខាន់ក្នុងការរាយការណ៍អំពីដំណើរការនៃការរៀបចំកន្លែងផ្តល់សេវាចម្រុះជូនអភិបាលខេត្ត និងសុំការអនុញ្ញាតពីការដាក់ឱ្យដំណើរការកន្លែងផ្តល់សេវាចម្រុះ ជាពិសេសត្រូវជានានិងសម្របសម្រួលឱ្យកន្លែងផ្តល់សេវាចម្រុះដំណើរការទៅដោយរលូន ស្របតាមតួនាទីនិងភារកិច្ចរបស់អ្នកផ្តល់សេវាពាក់ព័ន្ធ។

- **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត និងអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ៖**

ទទួលពាក្យបណ្តឹង ផ្តល់ប្រឹក្សាផ្នែកច្បាប់ ចុះអន្តរាគមន៍ ស៊ើបអង្កេតបឋម ប្រមូលភស្តុតាង ឃាត់ខ្លួន ចាប់ខ្លួន ឆែកឆេរ រៀបចំរបាយការណ៍ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។

- **មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖**

ផ្តល់សេវា និងស្វែងរកសេវាពីដៃគូពាក់ពន្ធ័ ដើម្បីស្តារនីតិសម្បទា និងធ្វើសមាហរណកម្ម និងតាមដានចំពោះករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

- **បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ៖**

ទទួលពាក្យបណ្តឹង ផ្តល់ប្រឹក្សាផ្នែកច្បាប់ ចុះអន្តរាគមន៍ ស៊ើបអង្កេតបឋម ប្រមូលភស្តុតាង ឃាត់ខ្លួន ចាប់ខ្លួន ឆែកឆេរ រៀបចំរបាយការណ៍ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។

- **មន្ទីរពេទ្យបង្អែករាជធានី ខេត្ត ឬមន្ទីរពេទ្យតំបន់៖**

ផ្តល់ទីកន្លែងផ្តល់សេវាចម្រុះ និងការពិនិត្យព្យាបាលថែទាំទាំងផ្លូវកាយ ទាំងផ្លូវចិត្តទៅតាមពិធីសារជាតិនិងធ្វើកំណត់ហេតុវេជ្ជសាស្ត្រសម្រាប់ការចេញលិខិតកោសល្យវិច័យតាមការស្នើសុំ។

- **មន្ទីរពេទ្យបង្អែកស្រុក ក្រុង ខណ្ឌ និងមណ្ឌលសុខភាព ៖**

ផ្តល់ប្រឹក្សា ព្យាបាល (ករណីរបួសស្នាមបន្ទាន់) និងបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យបង្អែករាជធានីខេត្ត និងផ្តល់ព័ត៌មានឱ្យក្រុមការងារសម្រាប់ទំនាក់ទំនង និងសម្របសម្រួលទៅអ្នកពាក់ព័ន្ធ។

- **តុលាការ៖**

ជាស្ថាប័នឯករាជ្យ និងមានសមត្ថកិច្ចក្នុងការទទួលពាក្យបណ្តឹងពីជនរងគ្រោះដោយផ្ទាល់ និងពីស្ថាប័ន មានសមត្ថកិច្ច។ ក្រោយពីបានទទួលពាក្យបណ្តឹង តុលាការត្រូវមានចំណាត់ការលើពាក្យបណ្តឹងទៅតាមសមត្ថកិច្ចរបស់ខ្លួន។ ការធ្វើចំណាត់ការលើបណ្តឹងដោយឈរលើគោលការណ៍ការពារយុត្តិធម៌ដល់(អ្នកស្វែងរកយុត្តិធម៌) ភាគីនៅក្នុងបណ្តឹងនិងអ្នកពាក់ព័ន្ធផ្សេងទៀតនៅក្នុងសំណុំរឿង។ តុលាការត្រូវពន្លឿននីតិវិធីក្នុងសំណុំរឿងដែលពាក់ព័ន្ធអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅគ្រប់ដំណាក់កាល។

- **មេធាវី៖**

  ពិគ្រោះនិងផ្តល់ប្រឹក្សាផ្នែកច្បាប់ ជាអ្នកតំណាង និងការពារសិទ្ធិនិងផលប្រយោជន៍ជូនកូនក្តី (ជនរងគ្រោះ ដើមបណ្តឹង អាចតំណាងនិងការពារឬអាចការពារជនជាប់ចោទ)។ រៀបចំពាក្យបណ្តឹង (សម្រាប់ជនរងគ្រោះ) និងតាក់តែងឯកសារចាំបាច់ផ្សេងៗនៅក្នុងរឿងក្តី ជាអ្នកបញ្ជូនឯកសារភស្តុតាង ដាក់បន្ទុក និងដោះបន្ទុកទៅតុលាការ និងចូលរួមជាមួយកូនក្តីនៅគ្រប់នីតិវិធីរបស់តុលាការ ដើម្បីការពារផលប្រយោជន៍របស់កូនក្តី។ មេធាវីត្រូវរក្សាការសម្ងាត់ជូនកូនក្តីនៅក្នុងសំណុំរឿងគ្រប់កាលៈទេសៈ តាមក្រមសីលធម៌វិជ្ជាជីវៈ។

- **អាជ្ញាធរថ្នាក់ក្រោមជាតិ៖**

  ផ្តល់កិច្ចសហការ ចូលរួមអន្តរាគមន៍ ផ្តល់ព័ត៌មាន គាំទ្រនិងសម្របសម្រួលបញ្ជូនជនរងគ្រោះមកទទួលសេវានៅកន្លែងផ្តល់សេវាចម្រុះ។

- **អង្គការដៃគូពាក់ព័ន្ធ៖**

  បញ្ជូននិងជួយគាំទ្រ ផ្តល់សេវាមេធាវី និងផ្តល់សេវាផ្សេងៗឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរួមមាន ប្រឹក្សាយោបល់ សេវាផ្លូវច្បាប់ ការធ្វើដំណើរ អាហារ ជម្រកស្នាក់នៅ ជំនាញវិជ្ជាជីវៈ។

## ៨.បរិយាកាសនៃការអនុវត្តនៅកន្លែងផ្តល់សេវាចម្រុះនិងលំហូរនៃការបញ្ជូនជនរងគ្រោះ

### ៨.១ ស្ថានភាពនៃការអនុវត្តកន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ

- **បន្ទប់ផ្តល់សេវាចម្រុះ៖** បន្ទប់ដែលត្រូវបានរៀបចំជាកន្លែងផ្តល់សេវាចម្រុះមិនបាច់ដាក់ស្លាកសញ្ញាមុខបន្ទប់ទេ។ បន្ទប់ដែលត្រូវបានប្រើប្រាស់ជាកន្លែងផ្តល់សេវាចម្រុះ ត្រូវរៀបចំនៅដាច់ដោយឡែកពីកន្លែងអ៊ូអរ ហើយមានសុវត្ថិភាពដល់ជនរងគ្រោះ (រក្សាការសម្ងាត់ ភាពឯកជនរបស់ពួកគេ) និងមានបំពាក់សម្ភារមួយចំនួនដែលមានរៀបរាប់នៅចំណុចខាងលើនិងត្រូវប្រាកដថា ជាកន្លែងដែលជនរងគ្រោះ ឬកូនៗរបស់ពួកគាត់ទទួលបាននូវសុខសុវត្ថិភាព ទាំងផ្លូវចិត្ត ទាំងផ្លូវកាយ ជាពិសេសប្រកចូលមកកន្លែងផ្តល់សេវាចម្រុះក៏ត្រូវប្រាកដថា មានការរក្សាការសម្ងាត់សម្រាប់ជនរងគ្រោះ។

- **នគរបាលឬកងរាជអាវុធហត្ថ៖** នគរបាលឬកងរាជអាវុធហត្ថដែលត្រូវចេញចូលកន្លែងផ្តល់សេវាចម្រុះតាមភារកិច្ចមិនត្រូវពាក់ឯកសណ្ឋានជានគរបាលឬកងរាជអាវុធហត្ថទេ ដើម្បីចៀសវាងការកត់សម្គាល់ អត្តសញ្ញាណជនរងគ្រោះឬ ករណីរបស់ជនរងគ្រោះពីអ្នកជំងឺទូទៅដទៃទៀត ដែលនឹងបណ្តាលឱ្យជនរងគ្រោះរងផលប៉ះពាល់ឯកជនភាព ការរក្សាការសម្ងាត់ និងសេចក្តីថ្លៃថ្នូររបស់ខ្លួន។ ប៉ុន្តែនគរបាលឬកងរាជអាវុធហត្ថអាចពាក់ឯកសណ្ឋានតាមករណីដែលមានសំណូមពរក្នុងករណីចាំបាច់ ហើយមានការឯកភាពក្រុមការងារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

❖ **គោលការណ៍ និងគុណតម្លៃទាំង៦សម្រាប់អ្នកផ្តល់សេវា៖** អ្នកផ្តល់សេវាពាក់ព័ន្ធត្រូវជានាយ៉ាងណា រាល់ពេលដែលពួកគាត់បញ្ជូនឬអមដំណើរមកជាមួយឬផ្តល់សេវាជូនជនរងគ្រោះ ត្រូវគោរពនិង អនុវត្តតាមគោលការណ៍ និងគុណតម្លៃទាំង៦ ដូចមានចែងក្នុងបទដ្ឋានអប្បបរមា រួមមាន៖

- **អភិក្រម សិទ្ធិមនុស្ស**
  អំពើហិង្សាទាក់ទងនឹងយេនឌ័រគឺជាការរំលោភបំពានសិទ្ធិមនុស្ស និងមិនអាចទទួលយក បានឡើយ ទោះជាអំពើនោះស្ថិតក្នុងទម្រង់អ្វីក៏ដោយ ។ នេះមានន័យថាជនប្រព្រឹត្តគឺជាអ្នក ទទួលខុសត្រូវចំពោះទង្វើនោះ មិនមែនជនរងគ្រោះឡើយ ។

- **ធានាសុវត្ថិភាព**
  អាទិភាពទី១គឺសុវត្ថិភាពរបស់ជនរងគ្រោះ។ រាល់សកម្មភាពទាំងអស់ត្រូវមានគោលបំណង ស្តារឡើងវិញ ឬរក្សាសុវត្ថិភាពរបស់ជនរងគ្រោះ និងមិនត្រូវឱ្យជនរងគ្រោះប្រឈមនឹង ហានិភ័យកាន់ តែច្រើនជាងមុននោះទេ ។

- **ការផ្តល់ភាពអង់អាចក្នុងការអនុវត្តជាក់ស្តែង**
  អនុវត្តវិធីសាស្ត្រដែលផ្តោតលើការយកចិត្តទុកដាក់លើជនរងគ្រោះ ការផ្តល់ព័ត៌មានអំពី ជម្រើសនានា អាចជួយជនរងគ្រោះក្នុងការធ្វើការសម្រេចចិត្តត្រឹមត្រូវសម្រាប់ខ្លួនឯង។ គោរព តាម និងស្តាប់យោបល់ គំនិតរបស់ជនរងគ្រោះ។ ខណៈពេលដែលព័ត៌មានអាចផ្តល់ភាព អង់អាចឱ្យជនរងគ្រោះធ្វើការសម្រេចចិត្តបានត្រឹមត្រូវ ជនរងគ្រោះមានសិទ្ធិធ្វើការសម្រេច ចិត្តថា តើពួកគេចង់បានជំនួយបែបណា ហើយអាចបដិសេធមិនទទួលសេវាណាក៏បាន ។

- **ឥរិយាបថមិនស្តីបន្ទោស និងវិនិច្ឆ័យ**
  ជនរងគ្រោះដោយអំពើហិង្សាដែលបង្កឡើងដោយដៃគូស្និទ្ធស្នាល អំពើហិង្សាផ្លូវភេទ ឬអំពើ ហិង្សាផ្សេងទៀត មិនត្រូវទទួលរងការស្តីបន្ទោស ដោយសារតែអំពើហិង្សាដែលពួកគេទទួល រងនោះឡើយ។ អំពើហិង្សាលើស្ត្រី គឺខុសនឹងច្បាប់របស់ប្រទេសកម្ពុជា ហើយជនប្រព្រឹត្ត អំពើហិង្សាត្រូវតែទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន។

- **រក្សាឯកជនភាពនិងរក្សាការសម្ងាត់**
  នៅគ្រប់ពេលទាំងអស់ត្រូវមានការគោរពភាពជាឯកជន និងរក្សាការសម្ងាត់របស់ជនរង គ្រោះ និងគ្រួសាររបស់ពួកគេ។ ការផ្តល់សេវាទាំងអស់គួរធ្វើឡើងនៅកន្លែងស្ងប់ស្ងាត់ ដែល អាចរក្សាភាពជាឯកជនបាន។ នៅពេលដែលជនងរងគ្រោះលើកឡើងអំពីអំពើហិង្សា ប្រសិនបើមានមនុស្សផ្សេងទៀតនៅជិតនោះ សូមឱ្យពួកគេចាកចេញឬទៅកន្លែងផ្សេង ដើម្បីកុំឱ្យអ្នកណាអាចស្តាប់ឮ ដើម្បីការពារភាពជាឯកជនរបស់ពួកគេបាន ។

មិនគួរយកអត្តសញ្ញាណជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ មកពិភាក្សាក្នុងកិច្ចប្រជុំណាមួយ ឬជាមួយអ្នកផ្តល់សេវាផ្សេងទៀតខាងក្នុង និងខាងក្រៅមូលដ្ឋានសុខាភិបាលដោយពុំមានការអនុញ្ញាតពីជនរងគ្រោះនោះទេ។ សម្រាប់ការពិគ្រោះយោបល់ ឬផ្តល់ដំបូន្មានអំពីរបៀបគ្រប់គ្រងករណី ដល់អ្នកផ្តល់សេវាផ្សេងទៀត សូមកុំប្រើប្រាស់ឈ្មោះរបស់ជនរងគ្រោះ លើកលែងតែមានការអនុញ្ញាតពីជនរងគ្រោះ។

- **ការមិនរើសអើង**

  ជនរងគ្រោះទាំងអស់ត្រូវទទួលបានការប្រតិបត្តិ និងទទួលបានសេវាដូចគ្នា។ មិនមានការរើសអើង ឬការប្រតិបត្តិផ្សេងគ្នាលើជនរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដោយសារតែជាតិពន្ធុ សាសនា វណ្ណៈសង្គម ពិការភាព អាយុ ទំនោរផ្លូវភេទឬកត្តាផ្សេងទៀតនោះទេ។

## ៨.២ លំហូរនៃការបញ្ជូនជនរងគ្រោះ

ការបញ្ជូនជនរងគ្រោះទៅរកសេវាដទៃទៀតនៅខាងក្រៅ ឬ សម្របសម្រួលជាមួយស្ថាប័នសេវាជំនាញដទៃទៀត ដើម្បីឱ្យមកផ្តល់សេវាដែលជនរងគ្រោះត្រូវការដល់បន្ទប់សេវាចម្រុះ អាចធ្វើទៅបាននៅពេលដែលមានសំណូមពរពីជនរងគ្រោះ ឬ បន្ទាប់ពីមានសេវានានាដែលអាចឆ្លើយតបនឹងតម្រូវការរបស់គាត់។

ការបញ្ជូនទៅរកសេវា និង ការសម្របសម្រួលការផ្តល់សេវានានា ត្រូវគោរព និងអនុវត្តតាមគោលការណ៍ និងគុណតម្លៃទាំង៦ ដូចមានចែងក្នុងបទដ្ឋានអប្បបរមា។

## គំរូកន្លែងផ្តល់សេវាចម្រុះ




## ៩. ការអភិវឌ្ឍសមត្ថភាពសមាជិកក្រុមការងារ និងអ្នកផ្តល់សេវាពាក់ព័ន្ធ

### ៩.១ កញ្ចប់បណ្តុះបណ្តាលពង្រឹងសមត្ថភាពរបស់អ្នកផ្តល់សេវាសម្រាប់ឆ្លើយតបនឹងជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ

ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពអំពីជំនាញសំខាន់ៗដល់សមាជិក និងអ្នកផ្តល់សេវាពាក់ព័ន្ធសម្រាប់ការអនុវត្តនៅកន្លែងផ្តល់សេវាចម្រុះជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ៖

- កញ្ចប់សេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សា (សេវាសុខាភិបាល សេវាយុត្តិធម៌និងនគរបាល សេវាសង្គម ការសម្របសម្រួល និងការគ្រប់គ្រងករណី)។
- បទដ្ឋានអប្បបរមាស្តីពី ការប្រឹក្សាយោបល់ជាមូលដ្ឋានសម្រាប់ស្ត្រី និងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។
- ពិធីសារជាតិ ស្តីពី ការថែទាំស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងវិស័យសុខាភិបាល។

- គោលការណ៍ណែនាំស្តីពី កិច្ចការពារតាមផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រីនៅកម្ពុជា។
- គោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រី និងក្មេងស្រីដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។
- គោលការណ៍ស្តីពីការគ្រប់គ្រងករណី និងប្រមូលទិន្នន័យករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។
- គោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ប្រព័ន្ធសុខាភិបាលស្តីពី ការគ្រប់គ្រងករណី។
- ការគ្រប់គ្រង និងថែទាំសុខភាពស្ត្រីរងគ្រោះដោយអំពើហិង្សាពីដៃគូស្និទ្ធស្នាល ឬអំពើហិង្សាផ្លូវភេទ។
- ការថែទាំសុខភាពស្ត្រីរងគ្រោះដោយអំពើហិង្សា សម្រាប់អ្នកគ្រប់គ្រងសេវាសុខាភិបាល។
- វគ្គបណ្តុះបណ្តាលផ្សេងៗទៀត តាមតម្រូវការចាំបាច់។

### ៩.២ វគ្គរំលឹកដល់អ្នកផ្តល់សេវាសម្រាប់ឆ្លើយតបនឹងជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ

វគ្គបណ្តុះបណ្តាលរំលឹកអំពីជំនាញសំខាន់ៗដល់អ្នកផ្តល់សេវាពាក់ព័ន្ធសម្រាប់ការអនុវត្តនៅកន្លែងផ្តល់សេវាចម្រុះជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រគឺជាភាពចាំបាច់ដែលអ្នករៀបចំ និងអ្នកផ្តល់សេវាត្រូវតែមាន អាចជា១ឆមាសម្តង ឬ១ឆ្នាំម្តង អាស្រ័យលើស្ថានភាព ឬភាពចាំបាច់។

## ១០. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

### ១០.១. ប្រព័ន្ធព័ត៌មាន ការកត់ត្រា និងរបាយការណ៍

កន្លែងផ្តល់សេវាចម្រុះ ត្រូវបង្កើតនៅក្នុងមន្ទីរពេទ្យសាធារណៈ ក្រោមការគ្រប់គ្រងនៅក្នុងវិស័យសុខាភិបាល ហេតុនេះក្រសួងសុខាភិបាល ចាំបាច់ត្រូវរៀបចំការគ្រប់គ្រងទិន្នន័យលើការគ្រប់គ្រងកន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

សម្រាប់ជនរងគ្រោះដែលត្រូវការរកជំនួយផ្នែកច្បាប់ ឯកសារវេជ្ជសាស្ត្រអាចជាឯកសារជំនួយឬភស្តុ-តាងដ៏មានប្រយោជន៍នៅក្នុងការប្រើប្រាស់តាមតម្រូវការ។ គ្រប់កិច្ចការផ្តល់សេវា ដល់ជនរងគ្រោះ ត្រូវមានការកត់ត្រាទាំងអស់ និងត្រូវរៀបចំជាឯកសារជាបញ្ជីកត់ត្រា វេជ្ជសាស្ត្រដូចជា៖ ឈ្មោះ អាយុ អាស័យដ្ឋាន ភេទ ទម្រង់នៃអំពើហិង្សា ទំនាក់ទំនងជាមួយអ្នករំលោភបំពាន ការព្យាបាលដែលបានផ្តល់ និងការបញ្ជូនជាដើម។

ការកត់ត្រា ប្រមូលទិន្នន័យ និងការធ្វើរបាយការណ៍ ជាការចាំបាច់សម្រាប់ការធានាគុណភាពការផ្តល់សេវា សម្រាប់ប្រើប្រាស់ទិន្នន័យ ដើម្បីវិភាគស្វែងយល់ពីស្ថានភាពបច្ចុប្បន្ននៃការគ្រប់គ្រង ការតាមដាននិងវាយតម្លៃពីវឌ្ឍនភាព ដំណើរការកន្លែងផ្តល់សេវាចម្រុះ។ ទិន្នន័យ អាចប្រើដើម្បីបង្កើតការយល់ដឹង និងយុទ្ធនាការតស៊ូមតិ និងការអភិវឌ្ឍន៍ការឆ្លើយតបតម្រូវការពីជនរងគ្រោះ។ ដូចគ្នានេះដែរ ការត្រួត

ពិនិត្យ និងការវាយតម្លៃអាចរួមចំណែកដល់ភស្តុតាងអំពីអ្វីដែលមានដំណើរការល្អ និងចំណុចខ្វះខាត ដែលត្រូវការការកែលម្អ។

ឯកជនភាពនិងការសម្ងាត់ក្នុងការប្រមូលទិន្នន័យ ការចែករំលែក និងការរាយការណ៍ ជាគោលការណ៍សំខាន់សម្រាប់ការពារអតិថិជន ឬជនរងគ្រោះពីការបង្កគ្រោះថ្នាក់បន្ថែមទៀតក្នុងទម្រង់នៃការមាក់ងាយ ការរើសអើង និងការសងសឹក។ មានតែការវិភាគសរុបប៉ុណ្ណោះដែលគួរត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ ប្រសិនបើករណីសិក្សាត្រូវបានបង្ហាញ នោះឈ្មោះត្រូវតែផ្លាស់ប្តូរ ហើយគ្មានព័ត៌មានដែលអាចកំណត់ពីអត្តសញ្ញាណបុគ្គល ។ ការកត់ត្រា កំណត់ហេតុវេជ្ជសាស្ត្រ ទាំងអស់គួរតែត្រូវបានរក្សាទុកនៅក្នុងទីតាំងមានសុវត្ថិភាព។ អ្នកផ្តល់សេវា កុំសរសេរការចង្អុលបង្ហាញអំពីអំពើហឹង្សានៅលើទំព័រដំបូងនៃកំណត់ហេតុ ការកត់ត្រាដែលអ្នកផ្សេងទៀតដែលមិនចាំបាច់ដឹងអាចមើលឃើញ ។ ត្រូវប្រាកដថាឯកសារត្រូវបានចាក់សោរជានិច្ចនៅក្នុងកន្លែងផ្តល់សេវា។ គ្មានចំណុចណាដែលគេគួរទុកឲ្យអ្នកផ្សេងអាចមើលឃើញឯកសារបានឡើយ។

**ក្រមសីលធម៌**

ដើម្បីការពារសិទ្ធិរបស់ស្ត្រីឬជនរងគ្រោះ ក្នុង ឯកជនភាពនិងការសម្ងាត់ ការវិភាគត្រូវតែបង្ហាញតែការវិភាគទិន្នន័យសរុប ឬសូចនាករប៉ុណ្ណោះ។ ព័ត៌មានដែលអាចកំណត់អត្តសញ្ញាណមិនគួរត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ ឬឯកសារណាមួយឡើយ។ OSSU អាចអនុវត្តតាមនីតិវិធីនេះ ដើម្បីធានាបាននូវក្រមសីលធម៌ ការវិភាគហ្មត់ចត់ និងបង្កើតភស្តុតាងតាមបែបវិទ្យាសាស្ត្រ។

## ១០.២.ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ

ការតាមដានត្រួតពិនិត្យ នឹងការវាយតម្លៃតាមពេលកំណត់ និងឬការវិភាគស៊ីជម្រៅលើការអនុវត្ត និងវឌ្ឍនភាពឆ្ពោះទៅរកគោលបំណង ឬទិដ្ឋភាពសំខាន់នៃការដំណើរការកន្លែងផ្តល់សេវាចម្រុះ។ ការតាមដានត្រួត ពិនិត្យ នឹងការវាយតម្លៃ អាចឆ្លើយកម្រងសំណួរអំពីគុណភាពសេវា ផលប៉ះពាល់នៃការធ្វើអន្តរាគមន៍ ការអនុលោមតាមស្តង់ដារ ការវាយតម្លៃចន្លោះប្រហោង និងជំហានដែលអាចធ្វើទៅបានដើម្បីកែលម្អការផ្តល់ សេវា។ កន្លែងផ្តល់សេវាចម្រុះ ត្រូវបានវាយតម្លៃដោយក្រុមការងារពីខាងក្រៅ ដើម្បីវាយតម្លៃសមិទ្ធិផលឆ្ពោះទៅរកគោលដៅ ក្នុងការរៀបចំសេវាអន្តរាគមន៍នៅតាមមន្ទីរពេទ្យ និងកំណត់លទ្ធភាពដែលអាចពង្រីកកន្លែង ផ្តល់សេវាបាន។ ការវាយតម្លៃធនធានរបស់ កន្លែងផ្តល់សេវា អាចត្រូវបានធ្វើឡើងដើម្បីឆ្លើយសំណួរដូចជា៖

- តើកន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ បានផ្តល់សេវាដោយភាពរលូន និងគ្រប់គ្រាន់ទេ?
- តើកន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ បានផ្តល់អត្ថប្រយោជន៍យ៉ាងដូម្តេចខ្លះ ដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ?
- តើត្រូវមានវិធានការអ្វីខ្លះ ដើម្បីកែលម្អគុណភាពសេវាឱ្យកាន់តែមានប្រសិទ្ធភាព?
- តើប្រព័ន្ធសុខាភិបាលបានរួមចំណែកដល់ការធ្វើឱ្យប្រសិទ្ធភាពចំពោះកន្លែងផ្តល់សេវាចម្រុះឆ្លើយតប អំពើហិង្សាទាក់ទងនឹងយេនឌ័រ យ៉ាងដូចម្តេចខ្លះ?
- តើអ្វីជាការរីកចម្រើនឆ្ពោះទៅរកគោលដៅដែលបានចែងក្នុងគម្រោង ឬកម្មវិធី?
- តើគោលដៅនៃគម្រោង ឬកម្មវិធីបានសម្រេចហើយឬនៅ?

ទិន្នន័យត្រួតពិនិត្យតាមដាន និងវាយតម្លៃ គួរតែត្រូវបានប្រើដើម្បីពិនិត្យ និងតាមដានការអនុវត្តប្រព័ន្ធគ្រប់គ្រហកន្លែងផ្តល់សេវាចម្រុះ និងធ្វើឱ្យមានភាពប្រសើរឡើងក្នុងការផ្តល់សេវាដូចខាងក្រោម៖

- ពិនិត្យឡើងវិញ ឬកែសម្រួលផែនការសម្រាប់សេវាកម្មដែលមានស្រាប់ ឬជូនដំណឹងអំពីផែនការសម្រាប់ពង្រីកសេវា។
- ផ្តល់មតិកែលម្អដល់បុគ្គលិកឬអ្នកផ្តល់សេវា លើការត្រួតពិនិត្យការរកឃើញ និងពិភាក្សាអំពីវិធីកែលម្អគុណភាពសេវាចម្រុះ ។
- ចែករំលែក ឬផ្សព្វផ្សាយការរកឃើញនៅក្នុងសហគមន៍ និងពិភាក្សាអំពីរបៀបធ្វើឱ្យប្រសើរឡើងនូវគុណភាពជាមួយសហគមន៍ រួមទាំងអង្គការដៃគូ អង្គការសង្គមស៊ីវិល និងវិស័យពាក់ព័ន្ធផ្សេង។
- កែលម្អពិធីដំណើរការ ឬនីតិវិធីប្រតិបត្តិការស្តង់ដារ។
- ផ្តល់ការបណ្តុះបណ្តាលបន្ថែមដល់អ្នកផ្តល់សេវាថែទាំសុខភាព។
- កែលម្អហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការផ្តល់សេវា និងពង្រឹងប្រព័ន្ធបញ្ជូន។

ការអនុវត្តកន្លែងផ្តល់សេវាចម្រុះជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងរបៀបនៃការផ្តល់សេវារបស់អ្នកផ្តល់សេវាត្រូវតែរៀបចំឱ្យមានប្រព័ន្ធ និងឧបករណ៍នៃត្រួតពិនិត្យតាមដាន របាយការណ៍នៃការអនុវត្ត និងការប្រជុំឆ្លុះបញ្ចាំងជាទៀងទាត់ជាប្រចាំឆមាស ឬប្រចាំឆ្នាំ។

# ឯកសារយោង

1 គេហទំព័ររបស់ UN Women (២០១៨) *Ending Violence Against Women* ថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០១៨។ http://www.unwomen.org/en/what-we-do/ending-violence-against-women.

2 អំពើហឹង្សាប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល (IPV) សំដៅទៅលើអាកប្បកិរិយាទាំងឡាយណានៅក្នុងទំនាក់ទំនងដៃគូស្និទ្ធស្នាលដែលបង្កឱ្យមានគ្រោះថ្នាក់ផ្លូវកាយ ផ្លូវចិត្ត ឬផ្លូវភេទចំពោះអ្នកដែលស្ថិតក្នុងទំនាក់ទំនងនោះ។ អំពើហិង្សានេះរួមមានទាំងអំពើហិង្សាផ្លូវកាយ អំពើហិង្សាផ្លូវភេទ អំពើហិង្សាផ្លូវចិត្ត រួមទាំងអាកប្បកិរិយាត្រួតត្រា និងអំពើហិង្សាផ្នែកសេដ្ឋកិច្ច។ អំពើហិង្សាក្នុងគ្រួសារគឺស្រដៀងគ្នាជាមួយពាក្យអំពើហិង្សាប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលដែរ ដោយពាក្យនេះសំដៅលើអំពើហិង្សាស្ថិតក្នុងទំនាក់ទំនងដៃគូស្និទ្ធស្នាល។ ក្នុងប្រទេសកម្ពុជា នៅក្នុងច្បាប់ស្តីពីការបង្ការអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ (២០០៥) អំពើហិង្សាក្នុងគ្រួសារត្រូវបានកំណត់និយមន័យថា ជាអំពើហិង្សារវាងប្តី ឬប្រពន្ធ ទៅលើកូនក្នុងបន្ទុក ឬជនដែលរស់នៅក្នុងផ្ទះជាមួយគ្នា និងដែលជាអ្នកស្ថិតក្នុងបន្ទុករបស់គ្រួសារ។ និយមន័យបែបចង្អៀតនេះ បានផ្តល់លទ្ធផលធ្វើឱ្យមានដែនកំណត់ ឬភាពខុសប្លែកមួយចំនួននៅក្នុងទិន្នន័យ ដែលនឹងត្រូវកំណត់ឃើញនៅពេលមានភាពពាក់ព័ន្ធ។

3 ការអង្កេតប្រជាសាស្រ្ត និងសុខភាពកម្ពុជាឆ្នាំ ២០២១-២០២២

4 ការអង្កេតប្រជាសាស្រ្ត និងសុខភាពកម្ពុជាឆ្នាំ ២០២១-២០២២

5...ក្រសួងកិច្ចការនារី (២០១៥) ការសិក្សាថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធន៍ជីវិតរបស់ស្រ្តីក្នុងប្រទេសកម្ពុជា រាជធានីភ្នំពេញ

6 ក្រសួងកិច្ចការនារី (២០១៤) ការសិក្សាអង្កេតស្តីពីអំពើហិង្សាលើកុមាររបស់ក្នុងប្រទេសកម្ពុជា រាជធានីភ្នំពេញ

7 ក្រសួងកិច្ចការនារី (២០១៤) ការសិក្សាអង្កេតស្តីពីអំពើហិង្សាលើកុមាររបស់ក្នុងប្រទេសកម្ពុជា រាជធានីភ្នំពេញ

គាំទ្រដោយ៖

UNFPA

Australian Aid

ACCESS 2
Sustainable quality services for all

USAID
FROM THE AMERICAN PEOPLE

USAID
EQHA II

Vital Strategies